# ការចាក់វ៉ាក់សាំងកូវីដ-១៩ សម្រាប់អ្នកអាយុ ១២-១៧

**ថ្នាំវ៉ាក់សាំងកូវ-១៩ Pfizer-BioNTech COVID-19 ឥឡូវអាចចាក់អោយអ្នកដែលមានអាយុចាប់ ពី ១២ ឆ្នាំឡើងទៅ។**

**ថ្នាំវ៉ាក់សាំងកូវីដ-១៩ មានសុវត្ថិភាពនិងប្រសិទ្ធភាពបំផុត។ គ្រប់វ៉ាក់សាំងកូវីដ-១៩** ទាំងអស់ត្រូវឆ្លងកាត់ការធ្វើតេស្តនិងពិនិត្យយ៉ាងម៉ត់ចត់មុនអាចយកមកប្រើការបាន។ **ក្រោយ**ពីបានតេស្តអ្នកចូលរួមជាង ២២៥០ នាក់ ក្នុងចំណោមអ្នកមានអាយុកម្រិតនេះ FDA បានអនុញ្ញាតវ៉ាក់សាំង Pfizer សម្រាប់ប្រើក្នុងគ្រាអាសន្នសម្រាប់ក្មេងអាយុពី ១២ ឆ្នាំឡើងទៅហើយគេមិនបានរកឃើញមានបញ្ហាសុវត្ថិភាពធ្ងន់ធ្ងរកើតឡើងទេ។ អ្នកជំនាញឯករាជ្យបានបញ្ជាក់ថា វ៉ាក់សាំងនេះ ស្របតាមស្តង់ដារសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។

**ថ្នាំ**វ៉ាក់សាំងកូវីដ-១៩ **ចាក់ដោយ**ឥតគិតថ្លៃហើយអាចចាក់បានដោយមិនគិតថា មានការធានារ៉ាប់រងសុខភាព ជាសញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍ឡើយ។ អ្នកផ្តល់សេវាកម្មមិនត្រូវទាមទាអោយអ្នកបង់ប្រាក់ទេ ប្រសិនបើអ្នកទៅជួបគេសម្រាប់តែចាក់វ៉ាក់សាំងប៉ុណ្ណោះ។

## វិធីរបៀបទទួលការចាក់វ៉ាក់សាំង

### ការស្វែងរកទីតាំងចាក់វ៉ាក់សាំង

- **សូមឆែកមើល**ជម្រើសនៃការចាក់វ៉ាក់សាំងក្នុងតំបន់ King County (ភាគច្រើនមិនត្រូវការដាក់ណាត់ជួបទេ) តាមរយៈ Kingcounty.gov/vaccine/khmer
- **សូម**ទូរស័ព្ទទៅការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកឬអ្នកផ្តល់សេវាកម្មថែទាំសុខភាពដើម្បីសួរគេថា តើពួកគេមានជម្រើសសម្រាប់ចាក់វ៉ាក់សាំងដែរឬទេ។
- ស្វែងរកឱសថស្ថាននិងទីតាំងផ្សេងទៀតដោយប្រើលេខស៊ីបកូដ តាមរយៈ vaccinelocator.doh.wa.gov/ (**សូម**ជ្រើសរើសភាសាដោយចុចលើប្រអប់ផ្នែកខាងលើនៅជ្រុងខាងស្តាំដៃ)
- **តើអ្នកត្រូវការជំនួយតាមទូរស័ព្ទដែរឬទេ?** សូមទូរស័ព្ទមកមជ្ឈមណ្ឌលទទួលបន្ទុកជំងឺកូវីដ-១៩ ក្នុងតំបន់យើងខោនធី នៅថ្ងៃណាក៏បាន ចន្លោះម៉ោង ៨ ព្រឹកដល់ ៧ ល្ងាច តាមរយៈលេខ 206-477-3977 ។ **មាន**អ្នកបកប្រែភាសា - **សូមប្រាប់**ភាសារបស់អ្នកនៅពេលគេភ្ជាប់ទូរស័ព្ទ។

### អ្វីដែលត្រូវយកមកជាមួយទៅកាន់ណាត់ជួបវ៉ាក់សាំងរបស់អ្នក:

- **ឯកសារបញ្ជាក់ពីអាយុ៖ អត្តសញ្ញាណប័ណ្ណពី**រដ្ឋ ពីកុលសម្ព័ន្ធ ឬ ពីសហព័ន្ធ លិខិតបញ្ជាក់កំណើតអត្តសញ្ញាណប័ណ្ណពីសាលារៀន ឬ ក្រដាស់ស្នាមពីសាលារៀនឬពីពេទ្យដែលមានឈ្មោះនិងថ្ងៃខែឆ្នាំកំណើតក៏អាចប្រើការបាន។
- **ការយល់ព្រមអោយចាក់វ៉ាក់សាំង។** អ្នកប្រហែលជាត្រូវការការយល់ព្រមពីឪពុកម្តាយឬមនុស្សពេញវ័យផ្សេងទៀតដែលជាអ្នកផ្តល់ការអនុញ្ញាតអោយអ្នកចាក់វ៉ាក់សាំងកូវីដ-១៩ ។ អ្នកអាចធ្វើការយល់ព្រមដោយខ្លួនឯងប្រសិនបើអ្នកមានករណីលើកលែងស្របច្បាប់ រៀបការជាមួយមនុស្សពេញវ័យ ឬ ទីតាំងចាក់វ៉ាក់សាំងកំណត់ថា អ្នកជាក្មេងគ្រប់វ័យ ។ **សូម**ស្វែងយល់បន្ថែមអំពីតម្រូវការយល់ព្រមតាមរយៈ Kingcounty.gov/youthvaccine/khmer ។
- **សូមពាក់អាវដៃ**ខ្លីឬដៃអាវរលុងដែលងាយនឹងទាញឡើងលើ។

**តើអ្នកមានសំណួរឬ? សូមមើលសំណួរដែលគេឧស្សាសួរជាញឹកញាប់នៅទំព័របន្ទាប់ឬចូលទៅ**
kingcounty.gov/covid/vaccine/khmer.

Public Health
Seattle & King County

## សំណួរដែលគេឧស្សាសួរជាញឹកញាប់អំពីការចាក់វ៉ាក់សាំង៖

### តើខ្ញុំត្រូវការចាក់ចំនួនប៉ុន្មានដង?

**ចំពោះថ្នាំវ៉ាក់សាំង** PFIZER អ្នកត្រូវចាក់ចំនួនពីរដង។ អ្នកនឹងចាក់លើកទី ២ យ៉ាងហោចណាស់ ២១ ថ្ងៃ ក្រោយពីបានចាក់លើកទី ១ រួច។ ចាក់លើកទី ១  ចាប់ផ្តើមបង្កើតភាពស៊ាំងនឹងជំងឺកូវីដ-១៩ ហើយចាក់លើកទីពីរ ធ្វើអោយមានប្រសិទ្ធភាពកម្រិតខ្ពស់បំផុតនិងគ្រប់កម្រិតការពារ។ អ្នកត្រូវបានគេចាត់ទុកថា អ្នកបានចាក់វ៉ាក់សាំងគ្រប់ចំនួន ២ សប្តាហ៍ ក្រោយពីបានចាក់លើកទី ២ រួច ។

### តើវាដូចគ្នានឹងថ្នាំវ៉ាក់សាំងដែលមនុស្សពេញវ័យចាក់មែនឬទេ?

ត្រូវហើយ វាគឺជាថ្នាំវ៉ាក់សាំង PFIZER ដូចគ្នាដែលមនុស្សពេញវ័យចាក់។ **អ្នក**ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ក៏អាចចាក់ថ្នាំវ៉ាក់សាំង MODERNA ឬ JOHNSON & JOHNSON បានដែរ ប៉ុន្តែថ្នាំវ៉ាក់សាំងនេះ គេមិនទាន់អនុញ្ញាតសម្រាប់អ្នកដែលក្មេងជាងនេះនៅឡើយទេ។

### តើខ្ញុំនឹងមានផលប៉ះពាល់ដែរឬទេ?

អ្នកប្រហែលជាអាចមានផលប៉ះពាល់ ដូចជា ឈឺដៃ ក្តៅខ្លួន ឈឺក្បាល ឬ ហត់នឿយក្នុងរយៈពេលពីរបីថ្ងៃក្រោយពីបានចាក់វ៉ាក់សាំងរួច។ នេះគឺជាសញ្ញាធម្មតាទេ ដែលប្រព័ន្ធភាពស៊ាំនៃរាងកាយរបស់អ្នកកំពុងតែបង្កើតការការពារ។ មនុស្សខ្លះមិនមានផលប៉ះពាល់អ្វីទាល់តែសោះ។

### តើខ្ញុំអាចកើតជំងឺកូវីដ-១៩ ពីថ្នាំវ៉ាក់សាំងឬទេ?

**អត់**ទេ។  មិនមានមេរោគកូរ៉ូនណានៅក្នុងថ្នាំវ៉ាក់សាំងទេ ហើយអ្នកមិនអាចកើតជំងឺកូវីដ-១៩ ពីថ្នាំេនះបានទេ។

### តើខ្ញុំអាចធ្វើអ្វីខ្លះនៅពេលដែលខ្ញុំបានចាក់វ៉ាក់សាំងគ្រប់គ្រាន់ហើយ?

អ្នកអាចចាប់ផ្តើមធ្វើអ្វីៗជាច្រើនឡើងវិញដែលត្រូវបានបញ្ឈប់ដោយសារជំងឺរាតត្បាតនេះ! អ្នកអាចជួបជុំគ្នានៅក្នុងផ្ទះជាមួយអ្នកដែលបានចាក់វ៉ាក់សាំងគ្រប់គ្រាន់ដោយមិនចាំបាច់ពាក់ម៉ាស់ (លើកលែងតែនៅទីប្រជុំជនឬទីកន្លែងសាធារណៈ) ។ អ្នកមិនចាំបាច់ពាក់ម៉ាសនៅខាងក្រៅទេ លើកលែងតែកន្លែងមានមនុស្សច្រើន។

**សូមតាមដាន**ព័ត៍មានថ្មីៗអំពីអ្វីដែលអ្នកអាចធ្វើបានក្រោយពីអ្នកបានចាក់វ៉ាក់សាំងរួចតាមរយៈ៖ LifeAfterVaccine.org

### តើខ្ញុំអាចជួបជុំគ្នាជាមួយអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងដោយមិនចាច់ពាក់ម៉ាស់ឬទេ?

**ក្រោយ**ពីអ្នកបានចាក់វ៉ាក់សាំងគ្រប់គ្រាន់ហើយ អ្នកអាចជួបជុំគ្នានៅក្នុងផ្ទះជាមួយមនុស្សពីមួយគ្រួសារដែលមិនទាន់បានចាក់វ៉ាក់សាំង ដោយមិនចាំបាច់ពាក់ម៉ាស់ ប្រសិនបើពួកគេមានហានិភ័យទាបឆ្លងជំងឺកូវីដ-១៩ (ឧទាហរណ៍ ពួកគេគ្មាននរណាម្នាក់មានបញ្ហាសុខភាពផ្សេងៗទៀត) ។ ប្រសិនបើមានមនុស្សលើសពីមួយគ្រួសារឬនរណាម្នាក់មានហានិភ័យខ្ពស់ អ្នកគួរតែពាក់ម៉ាស់ហើយរក្សាគម្លាតយ៉ាងតិច ៦ ហ្វីតពីគ្នា ហើយស្ថិតនៅទីកន្លែងដែលមានខ្យល់ចេញចូលល្អ (ដូចជានៅខាងក្រៅផ្ទះឬចំហរបង្អួច) ។ **ថ្នាំ**វ៉ាក់សាំងការពារអ្នកបានល្អ ប៉ុន្តែអ្នកជំនាញកំពុងតែសិក្សាថា តើអ្នកចាក់វ៉ាក់សាំងបានគ្រប់គ្រាន់ហើយ អាចចម្លងវីរុសដល់អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងដែរឬអត់។

### តើខ្ញុំអាចទៅទីកន្លែងណាដើម្បីស្វែងរកចម្លើយនូវសំណួរអំពីថ្នាំវ៉ាក់សាំងសម្រាប់ខ្ញុំឬក្រុមគ្រួសាររបស់ខ្ញុំ?

គ្រូពេទ្យឬអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ជានិច្ចកាល គឺជាអ្នកដែលអ្នកគួរសួរ។ អ្នកក៏អាចទទួលចម្លើយបន្ថែមទៀតតាមរយៈ  kingcounty.gov/covid/vaccine/khmer.